ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
លេខ៖ ..០៤៨..៣៣៩........./គ.ជ.អ.ប

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារបច្ចេកទេសស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

## គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

## (គ.ជ.អ.ប.)

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩/០៦ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- យោងលិខិតចាត់តាំងសមាសភាពចូលរួមក្នុងក្រុមការងាររបស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងមុខងារសាធារណៈ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងអប់រំ យុវជន និងកីឡា គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ ក្រសួងសុខាភិបាល ក្រសួងកិច្ចការនារី ក្រសួងបរិស្ថាន និងក្រសួងផែនការ

## សម្រេច

**ប្រការ ១._**

ត្រូវបានបង្កើតក្រុមការងារបច្ចេកទេសស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ហៅកាត់ថា ក.ប.អ.ប. ដើម្បីធានាបាននូវកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលក្នុងវិស័យកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. **ឯកឧត្តម សក់ សេដ្ឋា** | ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធានអចិន្ត្រៃយ៍នៃ គ.ជ.អ.ប. | ប្រធាន |
| ២. **ឯកឧត្តម ចាន់ សុធា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. | សមាជិក |
| ៣. **ឯកឧត្តម វង់ សណ្ដាប់** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤. **ឯកឧត្តម ម៉ុន ហុន** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៥. **លោកជំទាវ គីម ស៊ីផាត់** | រដ្ឋលេខាធិការប្រចាំការក្រសួងកិច្ចការនារី | សមាជិកា |
| ៦. **ឯកឧត្តម ហ៊ូ តាំងអេង** | រដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ៧. **ឯកឧត្តម ថោ សេដ្ឋាណា** | រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | សមាជិក |
| ៨. **ឯកឧត្តម សុខ សំអាង** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៩. **ឯកឧត្តម គីម ឆូច** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ១០.**ឯកឧត្តម ឡុង ប៉ុណ្ណាស៊ីរីវឌ្ឍ** | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១១. **ឯកឧត្តម អុល រ៉ូ** | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |

១២. **ឯកឧត្តម ចាយ សាមិត្ត** រដ្ឋលេខាធិការក្រសួងបរិស្ថាន សមាជិក

១៣. **លោកជំទាវ ឃុន រចនា** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា សមាជិកា

១៤. **ឯកឧត្តម ស្រ៊ុន តារា** អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

១៥. **ឯកឧត្តម ឈុន ម៉ុនណារ៉ា** អនុប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. សមាជិក

១៦. **លោក ម៉ុក ពុទ្ធី** ប្រធាននាយកដ្ឋានសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាល នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក។

**ប្រការ ២._**

ក្រុមការងារបច្ចេកទេស ក.ប.អ.ប. មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ពិនិត្យ និងផ្តល់យោបល់អំពីវឌ្ឍនភាពក្នុងការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ផែនការអនុវត្ត និងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ ជាពិសេសការពិនិត្យលើការអនុវត្តតាមសូចនាករត្រួតពិនិត្យរួម
- ធានាបាននូវការផ្តល់ព័ត៌មាន និងកិច្ចសហការជាទៀងទាត់ទៅលើគម្រោង និងកម្មវិធីដែលមានស្រាប់ និងដែលបានគ្រោងទុក ដើម្បីគាំទ្រដល់កម្មវិធីជាតិ ឬផែនការអនុវត្ត រួមទាំងការកំណត់នូវកង្វះខាតថវិកាគាំទ្រសម្រាប់ការគាំទ្រគម្រោង និងកម្មវិធីទាំងនោះ
- ពិនិត្យ និងផ្តល់អនុសាសន៍ជាយុទ្ធសាស្ត្រក្នុងការសម្របសម្រួល លើកកម្ពស់ការចូលរួម និងគាំទ្ររបស់សង្គមស៊ីវិលក្នុងការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- រៀបចំវេទិកាពិភាក្សា សម្របសម្រួល និងសុខដុមនីយកម្មរវាងកំណែទម្រង់អភិបាលកិច្ចនានា ពោលគឺ កំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កំណែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់ប្រព័ន្ធតុលាការ និងកំណែទម្រង់ច្បាប់ ព្រមទាំងកំណែទម្រង់តាមវិស័យនានា
- សម្របសម្រួល និងបន្សុីការគាំទ្រនានាដល់ការងារកំណែទម្រង់ ជាពិសេសកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិតាមរយៈវិធីសាស្ត្រសមស្របប្រកបដោយភាពស្រុះស្រួលគ្នា។

**ប្រការ ៣._**

លេខាធិការដ្ឋាន គ.ជ.អ.ប. ទទួលខុសត្រូវសម្របសម្រួលគាំទ្រដល់ ក.ប.អ.ប. ដើម្បីអនុវត្តមុខងារដែលបានកំណត់ប្រកបដោយប្រសិទ្ធភាព និងមានការចូលរួមពីភាគីពាក់ព័ន្ធ។

**ប្រការ ៤._**

ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ ក្រសួងសុខាភិបាល ក្រសួងផែនការ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកិច្ចការនារី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងបរិស្ថាន និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ៕

ថ្ងៃសុក្រ ១១កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធាន គ.ជ.អ.ប.**

**អភិសន្តិបណ្ឌិត ស សុខា**

**<u>កន្លែងទទួល ៖</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នជាសមាជិក គ.ជ.អ.ប.
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ